# ការឆែកពិនិត្យសុខភាពកូនរបស់លោកអ្នក មុនចូលអាយុ៤ឆ្នាំ

សូមបោះពុម្ពពាក្យវាយតម្លៃរបស់មាតាបិតា អំពីស្ថានភាពខាងការចំរើនលូតលាស់ (PEDS) មួយច្បាប់ដែលបកប្រែរួច ចេញពីវិបសាយ www.mhcs.health.nsw.gov.au ហើយបំពេញ មុនពេលលោកអញ្ជើញទៅ ឬស្នើសុំគិលានុបដ្ឋាកមើលថែសុខភាពកុមារឲ្យជួយបំពេញជូនលោកអ្នក។

## ការឆែកពិនិត្យមុនពេលចូលរៀន ក្នុងអាយុ៤ឆ្នាំ

## ការស្ទង់ប៉ាន់សុខភាព

មុនពេលកូនរបស់លោកអ្នកចាប់ផ្តើមចូលសាលារៀន លោកអ្នកត្រូវបានណែនាំឲ្យនាំកូនរបស់លោកអ្នកទៅឲ្យវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកមើលថែសុខភាពកុមារ និងគ្រួសារប្រចាំតំបន់របស់លោកអ្នកឆែកពិនិត្យសុខភាព។ ប្រសិនបើលោកអ្នកមិនអាចអញ្ជើញទៅបានទេ លោកអ្នកត្រូវស្នើសុំឲ្យមិត្តភ័ក្រ្ត ឬសាច់ញាតិនាំកូនរបស់លោកអ្នកធ្វើជំនួសលោកអ្នក។ ការឆែកពិនិត្យសុខភាពមានរួមទាំង:

- ការស្តាប់ឮ
- ការមើលឃើញ
- ការឆែកពិនិត្យលើរូបកាយ (កំពស់ ទម្ងន់ ដំណើរ)
- សំនួរទាក់ទិននឹងការចំរើនលូតលាស់របស់កូនលោកអ្នក
- ព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគ។

លោកអ្នកត្រូវបានលើកទឹកចិត្តឲ្យនិយាយប្រាប់គិលានុបដ្ឋាក វេជ្ជបណ្ឌិត ឬគ្រូបង្រៀនអំពីបញ្ហាសុខភាពណាមួយដែលអាចប៉ះពាល់ដល់សមត្ថភាពនៃការរៀនសូត្ររបស់កូនលោកអ្នក។

## ការឆែកពិនិត្យពងស្វាសក្នុងអាយុ៤ឆ្នាំ

ពងស្វាសរបស់កូនក្មេង អាចមើលឃើញ ឬស្ទាបដឹងនៅក្នុងថ្លោកពងស្វាសរបស់វា។ ពាក្យ "ពងស្វាស" ក៏ត្រូវបានគេស្គាល់ដែរថា "ពង"។ ពងស្វាសធម្មតាមានកម្ពស់ខុសគ្នាបន្តិច។ នេះគឺជាការធម្មតាទេដែលពងស្វាសមានកំរិតខ្ពស់ ឬទាបនៅក្នុងថ្លោកពងស្វាស នៅពេលខុសៗគ្នា (ឧទាហរណ៍ ខ្ពស់ជាងនៅក្នុងធាតុអាកាសត្រជាក់) ទោះជាយ៉ាងណាក្តី គេអាចមើលឃើញវាយ៉ាងហោចណាស់ គឺនៅពេលខ្លះវាធ្លាក់ចុះមកនៅក្រោមបំផុតនៃថ្លោកពងស្វាស។ វាអាចងាយស្រួលឆែកពិនិត្យពងស្វាសបំផុត នៅពេលកូនប្រុសរបស់លោកអ្នកក្តៅឧណ្ហៗ ហើយសំរាកស្រួល ឧទាហរណ៍ នៅក្នុងអាងទឹក។

ប្រសិនបើលោកអ្នកមិនអាចមើលឃើញពងស្វាសច្បាស់ទេ លោកអ្នកនឹងត្រូវការស្ទាបរកមើលវាតិចៗ នៅក្នុងថ្លោកពងស្វាស ដើម្បីឲ្យបានដឹងថាវានៅទីនោះ។ សូមប្រាប់កូនប្រុសរបស់លោកអ្នកឲ្យបានដឹងថា វាជាការសំខាន់ដែលត្រូវដឹងថាពងស្វាសរបស់វានៅចំកន្លែង ក៏ប៉ុន្តែសូមបញ្ជាក់ប្រាប់វាកុំឲ្យខ្វល់ព្រួយអំពីរឿងនេះ។ សូមឲ្យបានជាក់លាក់ថាដៃរបស់លោកអ្នកក្តៅឧណ្ហៗ ដោយព្រោះថាធម្មតាពេលខ្លះពងស្វាសអាចរត់ឡើង ចេញពីថ្លោកពងស្វាសកាលណាប៉ះដោយដៃត្រជាក់។ ប្រសិនបើលោកអ្នកមិនអាចមើលឃើញ ឬស្ទាបដឹងពងម្ខាងមួយ ឬទាំងពីររបស់កូនលោកអ្នក ឬលោកអ្នកមិនអាចឆែកពិនិត្យវាបានទេ សូមឲ្យវេជ្ជបណ្ឌិតឆែកមើលវា។ វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកនឹងពេញចិត្តពិភាក្សាអំពីរឿងនេះជាមួយលោកអ្នក ក្នុងពេលឆែកពិនិត្យសុខភាពរបស់កូនលោកអ្នក។

| សំនួរដល់មាតាបិតាពីការមើលឃើញ និងការស្តាប់ឮ | បាទ/ចាស៎ | ទេ | មិនប្រាកដ |
| --- | --- | --- | --- |
| តើលោកអ្នកមានកង្វល់អំពីការមើលឃើញរបស់កូនលោកអ្នកឬ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកមានភ្នែកស្រលៀងឬទេ? | ☐ | ☐ | ☐ |
| តើក្នុងពេលបច្ចុប្បន្ននេះ តើកូនរបស់លោកអ្នកបិតនៅក្រោមការមើលថែ សំរាប់ការមើលឃើញរបស់វាឬទេ? | ☐ | ☐ | ☐ |
| តើលោកអ្នកមានកង្វល់អំពីការស្តាប់ឮរបស់កូនលោកអ្នកឬ? | ☐ | ☐ | ☐ |
| ក្នុងឆ្នាំកន្លងទៅ តើកូនរបស់លោកអ្នកធ្លាប់កើតរោគអំបៅអំបែកឬទេ? | ☐ | ☐ | ☐ |
| ក្នុងឆ្នាំកន្លងទៅ តើកូនរបស់លោកអ្នកធ្លាប់កើតមានដំបៅត្រចៀកលើសពី៤ដងឬទេ?? | ☐ | ☐ | ☐ |
| នៅពេលកើតគ្រុនផ្តាសាយ តើកូនរបស់លោកអ្នកមានបញ្ហាក្នុងការស្តាប់ឮឬទេ? | ☐ | ☐ | ☐ |
| តើជាញឹកញយកូនរបស់លោកអ្នកដែលស្នើសុំឲ្យលោកអ្នកនិយាយម្តងទៀតឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកមានការលំបាកធ្វើតាមការណែនាំឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកនិយាយបានច្បាស់ឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកប្រើចង្កោមពាក្យឬទេ នៅពេលនិយាយ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកដើរតាមទិសដៅឬទេ? | ☐ | ☐ | ☐ |
| rតើកូនរបស់លោកអ្នករួមចំណែកយ៉ាងសកម្មក្នុងការនិយាយគ្នាឬទេ? | ☐ | ☐ | ☐ |